**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ រវាង

លោក ស៊ិន សារ៉េត កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០៥០៨៥៥៩៥៦ ដែលមានតួនាទី **ប្រធានផ្នែកគ្រប់គ្រងរោងនីយដ្ឋាន** និងជាតំណាងភាគីនិយោជក នៃក្រុមហ៊ុន **ហ្វ៊ូដឡាយហ្វ៍ ៦.ក** ដែលមានអាសយដ្ឋានស្ថិតនៅផ្ទះលេខ២៥ ផ្លូវ៥២៨ កែងផ្លូវ២៨៣ សង្កាត់បឹងកក់១ ខណ្ឌសែនសុខ រាជធានីភ្នំពេញ និង លោក ហេង ថាន់ កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០២០៩៣១០៩៤ ដែលមានតួនាទីជា **មេផ្នែកចុងភៅ** និងជា តំណាងភាគីនិយោជិក នៃក្រុមហ៊ុនខាងលើ។

ភាគីទាំងពីរបានធ្វើការព្រមព្រៀងគ្នាដូចខាងក្រោមៈ

០១- **រយៈពេលនៃការព្យួរកិច្ចសន្យាការងារៈ**

ការព្យួរកិច្ចសន្យាការងារ ចាប់ពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ចំនួនកម្មករសរុប ១៣០ នាក់ ស្រី ៦៥នាក់ កម្មករព្យួរកិច្ចសន្យាការងារមាន ៦១នាក់ ស្រី ២៩នាក់ មូលហេតុដោយសារ ក្រុមហ៊ុនបានទទួលរងនូវផលប៉ះពាល់យ៉ាងអវិជ្ជមានលើផ្នែកហិរញ្ញវត្ថុ ដែលបង្កដោយវីរុស កូវីដ១៩។

០២- **ប្រាក់ឧបត្ថម្ភកំឡុងពេលព្យួរកិច្ចសន្យាការងារៈ**

ភាគីនិយោជក មិនមានផ្តល់ជាប្រាក់ឧបត្ថម្ភអ្វីឡើយ កំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។

ភាគីនិយោជិក មិនទាមទារប្រាក់ឧបត្ថម្ភអ្វីឡើយ ពីនិយោជកក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះ។

០៣- **កាលបរិច្ឆេទចូលបម្រើការងារវិញៈ**

បុគ្គលិកនិយោជិកទាំងអស់ត្រូវត្រឡប់ចូលមកបម្រើការងារវិញ បន្ទាប់ពីរយៈពេលព្យួរកិច្ចសន្យាការងារនេះត្រូវបានបញ្ចប់។ កិច្ចសន្យានេះត្រូវបានធ្វើឡើងជាពីរ(០២)ច្បាប់និងមានតម្លៃស្មើគ្នាចំពោះមុខច្បាប់ដែលសម្រាប់ភាគីនីមួយៗទុកម្នាក់មួយ(០១)ច្បាប់។

ភាគីទាំងពីរបានអាន ព្រមព្រៀងគ្នា និងបានផ្តិតមេដៃ ដើម្បីជាសាក្ខីភាព៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១

តំណាងភាគីនិយោជិក

តំណាងប្រតិភូពេញសិទ្ធ

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ហ្វ៊ូដឡាយហ្វ៍ ៦.ក FOODLIFE CO., LTD. KINGDOM OF CAMBODIA

ហេង ថាន់ សាន ស្រីលក្ខ ចៅ ភារ៉ាលីលី រ៉ុម ណារិន

លោក ស៊ិន សារ៉េត